# សេចក្តីថ្លែងរបស់មណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិច នៃក្រុមប្រឹក្សាភិបាលមូលនិធិសកល

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលមូលនិធិសកល លើកទី៤២
ទីក្រុងហ្សឺណែវ ថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០១៩

## 1. ការប្រជុំគៀងគរបំពេញធនធានលើកទី៦

មណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិច សូមថ្លែងនូវការកោតសសើរជូនសាធារណរដ្ឋបារាំង ចំពោះជោគជ័យ នៃកិច្ចប្រជុំ គៀងគរបំពេញធនធានលើកទី៦ ដែលបានប្រព្រឹត្តទៅនៅទីក្រុងលីយ៉ុង កាលពីថ្ងៃទី៩-១០ ខែតុលា ឆ្នាំ២០១៩កន្លងទៅនេះ។ យើងសូមសម្តែងនូវការកោតសសើរចំពោះ ការដឹកនាំរបស់លោកប្រធានាធិបតី ម៉ានុយអែល ម៉ាក្រុង ដែលបានទទួលជាម្ចាស់ផ្ទះនៃកិច្ចប្រជុំ និងបានរៀបចំកិច្ចប្រជុំដ៏មានសារសំខាន់នេះ។

លើសពីនេះ មណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិច សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ម្ចាស់អំណោយទាំងអស់ ដែលបានសន្យារផ្តល់ជំនួយហិរញ្ញវត្ថុប្រមាណ១៤ពាន់លាន ដុល្លាសហរដ្ឋអាមេរិក សំរាប់រយៈបន្ទាប់ពី២០២០-២០២២។ នេះមានន័យថា សាមគ្គីភាពអន្តរជាតិ ស្ថិតស្ថេរ ក្នុងការលុបបំបាត់ជំងឺអេដស៍ របេង និងគ្រុនចាញ់។

មណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិច សូមថ្លែងអំណរគុណ ជូនដល់ភាពជាអ្នកដឹកនាំ នៃក្រុមប្រឹក្សាភិបាលមូលនិធិសកល នាយកប្រតិបត្ត លេខាធិការដ្ឋាន មូលិធិសកល ក៏ដូចជា តំណាងសហគមន៍រងការប៉ះពាល់នៃជំងឺទាំង៣ ដែលបានបំពេញកិច្ចការជាមួយ ការការលះបង់ នឿយហត់ និងប្រកបដោយប្រសិទ្ធភាព ឈានទៅសម្រេចជោគជ័យគៀងគរបំពេញបន្ថែមធនធានហិរញ្ញវត្ថុ នៃមូលនិធិសកល ។

## 2. ប្រភពនៃធនធាន ដែលត្រូវបែងចែកសំរាប់រយៈពេលគម្រោង២០២០-២០២២

មណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិច ឯកភាពវិធីសាស្ត្របែងចែក ដែលក្នុងនោះ ហិរញ្ញវត្ថុ ៨៩០ លានដុល្លាសហរដ្ឋអាមេរិក នឹងត្រូវបានចំណាយជំរុញការវិនិយោគ ហើយ ប្រមាណ ១២.៧១ ពាន់លានដុល្លាសហរដ្ឋអាមេរិក នឹងត្រូវបានបែងចែកជូនប្រទេសទទួលជំនួយ សម្រាប់រយៈពេល គម្រោង២០២០-២០២២។ យើងសូមផ្តល់អនុសាសន៍ ប្រទេសដែលមានបន្ទុកជំងឺធ្ងន់ធ្ងរជាង គួរត្រូវបានផ្តល់មូលនិធិជំនួយច្រើនជាង។ ដើម្បីអោយក្រុមប្រទេសទាំងនោះ អាចឈានដល់ ដំណាក់កាល លុបបំបាត់ជំងឺអេដស៍ របេង និងគ្រុនចាញ់ ត្រឹមឆ្នាំ២០៣០ តាមការផ្តល់យោបល់ ដោយសហគមន៍សុខាភិបាលពិភពលោក។

ប៉ុន្តែ ប្រទេសដែលរងការប៉ះពាល់ដោយជំងឺទាំង៣ ស្រាលជាង គួរតែត្រូវបានគិតគូរផងដែរ។ យើងសូមផ្តល់អនុសាសន៍ដោយទទូច ជូនមូលនិធិសកលថា សូមវិនិយោគបន្ថែមទៀតអំពី ការប្រយុទ្ធនឹងជំងឺដោយមាននិរន្តរភាព និងមានភាពរឹងមាំ នៃប្រព័ន្ធសុខាភិបាល ដើម្បីធានាថា

ប្រទេសទទួលជំនួយ អាចបន្តនិរន្តរភាពប្រព័ន្ធសុខាភិបាលរបស់ពួកគេ នៅគ្រាដែលជំនួយពីខាងក្រៅ ប្រទេស ត្រូវបានកាត់បន្ថយ។ យើងសូមផ្តល់អនុសាសន៍ដោយភាពជឿជាក់ ថា បញ្ហាប្រឈមមួយ ចំនួនដូចជា អភិបាលកិច្ចល្អ និង សិទ្ធមនុស្ស គួរត្រូវបានដោះស្រាយដោយមានកាចូលរួមកាន់តែ ល្អប្រសើឡើងពីអង្គការសង្គមស៊ីវិល ។

### 3. ការវិវត្តនៃកាសាកល្បងប្រព័ន្ធលទ្ធកម្ម ឆ្លើយតបតម្រូវការផ្តត់ផ្គង់អោយគម្រោងគាំទ្រហិរញ្ញវត្ថុក្រៅពីមូលនិធិសកល

មណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិច ទទួលស្គាល់ពីសារៈសំខាន់នៃការអភិវឌ្ឍកាសាកល្បងប្រព័ន្ធលទ្ធកម្ម និងគាំទ្រគម្រោងសាកល្បងនេះ។ ពាក់ព័ន្ធជាមួយការវិវត្តនេះ យើងសូមផ្តល់អនុសាសន៍ សូមផ្តល់លទ្ធភាពអោយបានប្រើប្រាស់ប្រព័ន្ធនេះសំរាប់ការផ្គត់ផ្គង់ ផលិតផល សេវាមុខងារផ្សេងៗ ជូនគម្រោងទាំងឡាយគ្រប់គ្រងដោយរដ្ឋាភិបាល ឬ អង្គការជាដៃគូអភិវឌ្ឍ មិនមែនរដ្ឋាភិបាល នៃប្រទេសដែលមានល័ក្ខខ័ណ្ឌជាប្រទេសត្រូវទទួលជំនួយពីទទួលមូលនិធិសកល និង ស្ថិតនៅក្នុងដំណាក់កាលផ្ទេរ ទោះជាមានប្រភពហិរញ្ញប្បទានផ្សេងពីមូលនិធិសកលក្តី។

មណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិច ទទួលស្គាល់ថាមានតម្រូវការបណ្តុះបណ្តាលជូនប្រទេសមួយចំនួនដើម្បីអាចប្រើប្រាស់ប្រព័ន្ធនេះបានល្អ និង អាចមានជម្រើសច្រើនប្រភេទ ស្របតាម ជ្រើសរើសទំនិញ បំពេញតាមតម្រូវការផ្សេងៗគ្នា។

### 4. លេខាធិការដ្ឋាន និង ការិយាល័យអធិការកិច្ច សូមធ្វើការរួមគ្នា ធ្វើអោយប្រសើឡើងទិន្នន័យប្រទេស និង ការគ្រប់គ្រងសារពើភ័ណ្ឌ

មណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិច លើកទឹកចិត្តអោយ លេខាធិការដ្ឋាន និង ការិយាល័យអធិការកិច្ច ស៊ើបអង្កេត ធ្វើការជាមួយគ្នា បន្តធ្វើអោយប្រសើឡើងទិន្នន័យប្រទេស និង ការគ្រប់គ្រង សារពើភ័ណ្ឌ រួមទាំងខ្សែសង្វាក់ផ្គត់ផ្គង់។ យើងជឿជាក់ថា ទិន្នន័យត្រឹមត្រូវ ការគ្រប់គ្រងសារពើភ័ណ្ឌ ល្អ រួមជាមួយធនធានមនុស្សដែលមានសមត្ថភាព នឹងជួយពង្រឹងអោយរឹងមាំប្រព័ន្ធសុខាភិបាល ប្រទេសទទួលជំនួយ។

### 5. និរន្តរភាព និងដំណាក់កាលផ្ទេរ

មណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិច ធ្វើការកត់សម្គាល់ដោយការកោតសសើរ កិច្ចការដែលបានបំពេញដោយក្រុមគណៈកម្មការត្រួតពិនិត្យបច្ចេកទេស (Technical Review Panel) និងសូមឯកភាពជាមួយ អនុសាសន៍ របស់ក្រុមគណៈកម្មការ

- ផែនការនិរន្តរភាពត្រូវបានចងក្រងដោយប្រទេសសាមីទាំងអស់ ដូច្នេះសំណើរ សុំមូលនិធិគម្រោង នឹងផ្តោតលើ និរន្តរភាពកម្មវិធី និងហិរញ្ញវត្ថុ ការប្រើប្រាស់ប្រព័ន្ធ

ប្រទេសអោយបានកាន់តែប្រសើឡើង រួមទាំងយន្តការផ្តល់សេវាដែលមាន និរន្តរភាពយូរអង្វែង សំរាប់ក្រុមប្រជាជនរងការប៉ះពាល់ជាងគេ។

- ការកសាងផែនការ ត្រូវបានធ្វើឡើងចាប់ពីដំបូងទី

ក្នុងអំឡុងពេលអនុវត្តគម្រោងជំនួយ មណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិច មានជំនឿថា មូលនិធិសកល សហការជាមួយអង្គការសុខភាពពិភពលោក កម្មវិធីអង្គការសហប្រជាជាតិប្រយុទ្ធនឹងជំងឺអេដស៍ (UNAIDS) គម្រោងកម្មវិធីឆ្លើយតបបន្ទាន់ទៅនឹងជំងឺអេដស៍របស់ប្រធានាធិបតីសហរដ្ឋអាមេរិក (កម្មវិធីផេបហ្វា) PMI ត្រូវបន្តលើកទឹកចិត្តរដ្ឋាភិបាល កសាងផែនការយុទ្ធសាស្ត្រ និរន្តរភាព និង ផ្ទេរ អោយបានតាំងពីដំបូងទី ដោយចាប់ផ្តើមពីដំណាក់កាលដំបូងនៃការធ្វើផែនការ រហូតដល់ដំណាក់កាលអនុវត្តចុងក្រោយ។ យើងសូមផ្តល់អនុសាសន៍ថា ជំនួយបច្ចេកទេសផ្តល់ជូនទៅអោយប្រទេសទទួលជំនួយណា ដែលបានបង្ហាញពីភាពដឹកនាំ និង ភាពជាម្ចាស់ នៅគ្រប់ដំណាក់កាល។ យើងជឿជាក់ថា មូលនិធិសកល អ្នកផ្តល់អំណោយផ្សេងទៀត និងរដ្ឋាភិបាលទទួលជំនួយអាចធ្វើការជាមួយគ្នា តាមរយៈក្រុមការងារបច្ចេកទេសរួម ដើម្បីតាមដានវឌ្ឍនភាពនៃ ការអនុវត្តយុទ្ធសាស្ត្រ។

## 6. ការវិវត្តនៃយន្តការសម្របសម្រួលគម្រោងមូលនិធិសកលរបស់ប្រទេសទទួលជំនួយ

a. មណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិច ពេញចិត្តជាមួយលទ្ធផល និងរបកគំហើញ នៃវគ្គទី១ ហើយយើងគាំទ្រផែនការបន្តទៀត
b. មណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិច មានការបារម្ភអំពី និរន្តរភាពដែលមានក្រោមគំនិតផ្តួចផ្តើមនេះ។ វាមានសារៈសំខាន់ណាស់ដែលមូលនិធិសកល សហការជាមួយប្រទេសទទួលជំនួយ ធានានិរន្តរភាពរបស់យន្តការសម្រប សម្រួលគម្រោងមូលនិធិសកលរបស់ប្រទេសទទួលជំនួយ ដើម្បីទទួលខុសត្រូវបំពេញភារកិច្ច របស់ខ្លួន។
c. មណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិច រង់ចាំសហការសំរាប់វគ្គបន្ទាប់

## 7. វប្បធ៌មនៃអភិបាលកិច្ច

a. មណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិច ឯកភាពជាមួយខ្លឹមសារវគ្គ២ នៃគំនិតផ្តួចផ្តើមវប្បធ៌មអភិបាលកិច្ច
b. មណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិច នឹងនាំយកខ្លឹមសារវគ្គ២នោះ ផ្តល់ជូនទៅយន្តការសម្របសម្រួលគម្រោងមូលនិធិសកលរបស់ប្រទេសទទួលជំនួយ ដើម្បី ធ្វើការពិចារណា និងធ្វើសកម្មភាពជាបន្តទៀត។